អ អ ក

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ ១៥៦ ស.ក.១៥អអក

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ភ្នំពេញ, ថ្ងៃទី២៥ ខែ កុម្ភៈ ឆ្នាំ២០១៥

# លិខិតអនុញ្ញាត

## អាជ្ញាធរអគ្គិសនីកម្ពុជា

- អនុវត្តតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើ ដោយ ព្រះរាជក្រម លេខនស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១
- អនុវត្តតាមការកំណត់របស់អនុក្រឹត្យ លេខ៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីគោលការណ៍វាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី
- អាជ្ញាប័ណ្ណរួមលេខ២៥០.អ ចេញឲ្យលោកស្រី ស៊ុយ ចំណាន នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៩
- យោងសេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា លេខ០៥៨.សរ-១៥-អអក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០១៥
- យោងតាមតម្លៃប្រេងម៉ាស៊ូតលើទីផ្សារ ក្នុងខែមករា ឆ្នាំ២០១៥
- យោងតាមចំណារឯកភាពលើកំណត់បង្ហាញរបស់នាយកដ្ឋានបញ្ជីថ្លៃលក់ និងត្រួតពិនិត្យគណនេយ្យ សេវាកម្ម លេខ០២៩-១៥-បថល ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥

## អនុញ្ញាត

**ប្រការ ១** -

ផ្អែកតាមតារាងថ្លៃលក់អគ្គិសនីនៅក្នុងប្រការ១ នៃសេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា លេខ ០៥៨.សរ-១៥-អអក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥ និងផ្អែកលើមូលដ្ឋានថ្លៃប្រេងម៉ាស៊ូតនៅលើទីផ្សារជាមធ្យម នៅក្នុងខែមករា ឆ្នាំ២០១៥ មានតម្លៃស្មើនឹង ៧៥៧ (ប្រាំពីររយហាសិបប្រាំពីរ) ដុល្លារអាមេរិកក្នុង១តោន អាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចអនុញ្ញាតឲ្យសេវាករ ស៊ុយ ចំណាន អ្នកកាន់អាជ្ញាប័ណ្ណលេខ២៥០.អ ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់ទូទៅ នៅឃុំកោះឧញ៉ាតី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល អនុវត្តអត្រាថ្លៃលក់ស្មើនឹង២,៤០០ (ពីរពាន់បួនរយ) រៀលក្នុង១ គីឡូវ៉ាត់ម៉ោង។

**ប្រការ ២** -

អត្រាថ្លៃលក់អគ្គិសនីថ្មីខាងលើនេះ ត្រូវបានអនុញ្ញាតឱ្យអនុវត្តចំពោះការចេញ"វិក្កយបត្រថ្លៃអគ្គិសនី" ចាប់ពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥ តទៅ រហូតដល់មានការអនុញ្ញាតជាថ្មីដោយអាជ្ញាធរអគ្គិសនីកម្ពុជា ទៅតាមកម្រិតថ្លៃប្រេងម៉ាស៊ូតលើទីផ្សារ។ អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវផ្លាស់ប្តូរខួប និងពេលវេលាក្នុងការកត់ត្រាលេខអំណាននាឡិកាស្ទង់ កាលបរិច្ឆេទនៃការចេញវិក្កយបត្រថ្លៃអគ្គិសនី និងការបែងចែកក្រុមអតិថិជនទេក្នុងការអនុវត្តអត្រាថ្លៃលក់អគ្គិសនីថ្មីខាងលើ។ បញ្ជីថ្លៃលក់អគ្គិសនីចាស់ ដែលបានដាក់ឱ្យប្រើប្រាស់ ត្រូវចាត់ទុកជានិរាករណ៍ ចាប់ពីពេលអនុវត្តបញ្ជីថ្លៃលក់អគ្គិសនីថ្មីនេះ។

**ប្រការ ៣** -

ការអនុវត្តអត្រាថ្លៃលក់អគ្គិសនីនេះ មានប្រសិទ្ធភាពអនុវត្តចំពោះអ្នកប្រើប្រាស់អគ្គិសនីដែលឋិតនៅក្នុងតំបន់ចែកចាយរបស់សេវាករ ស៊ុយ ចំណាន ប៉ុណ្ណោះ។

**ប្រការ ៤** -

សេវាករ ស៊ុយ ចំណាន មានភារកិច្ចផ្សព្វផ្សាយអំពីការអនុញ្ញាតនេះ ដល់អតិថិជនរបស់ខ្លួនគ្រប់ប្រភេទដែលពាក់ព័ន្ធ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

EAC

**បណ្ឌិត.ឆី នីរិន្ទ**

<u>ចម្លងជូន:</u>

- ក្រសួង រ៉ែ និងថាមពល
- សាលាខេត្តកណ្តាល
- មន្ទីរ រ៉ែ និងថាមពល ខេត្តកណ្តាល
- សាលាស្រុកខ្សាច់កណ្តាល
- សាលាឃុំកោះឧញ៉ាតី

"ដើម្បីជូនជ្រាប"

- សេវាករ ស៊ុយ ចំណាន "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- ឯកសារ-កាលប្បវត្តិ